# ការប្រឹក្សាយោបល់ស្តីពីគោលនយោបាយ

*ដំណើរការតាមមូលដ្ឋាន 2024 - 2*

**គោលនយោបាយ៖ ការបិទបញ្ចប់សំណើដែលបានបោះបង់ចោលនៅក្នុងប្រព័ន្ធ BRC Manager**
**កាលបរិច្ឆេទចូលជាធរមាន៖** ថ្ងៃទី 1 ខែកុម្ភៈ ឆ្នាំ 2024
តំណភ្ជាប់គោលនយោបាយ៖ https://www.mass.gov/doc/eec-closing-abandoned-requests-in-brc-manager-policy-documentkhmer/download

## សេចក្តីសង្ខេបរួម

ដើម្បីធានាថា បញ្ជីសំណើសុំមិនទាន់បានសម្រេចស្តីពីការត្រួតពិនិត្យសារគារ (Background Record Check, BRC) គឺមានបច្ចុប្បន្នភាព និងរួមបញ្ចូលតែអ្នកដាក់ពាក្យសុំទាំងឡាយណាដែលមានផ្តិតស្នាមម្រាមដៃនោះ ស្ថាប័ន EEC នឹងបិទបញ្ចប់សំណើ BRC នៅក្នុងប្រព័ន្ធ BRC Manager ក្នុងរយៈពេល 120 ថ្ងៃបន្ទាប់ពីប្រគល់ជូន ប្រសិនបើបេក្ខជនមិនបានផ្តល់ស្នាមម្រាមដៃនៅត្រឹម ពេលវេលានោះទេ។

គោលនយោបាយនេះនឹងប៉ះពាល់ដល់សំណើ BRC សម្រាប់បេក្ខជនចាស់ៗទាំងអស់ រួមទាំងបេក្ខជនចាស់ៗទាំងឡាយណាដែលស្ថិតនៅក្នុងស្ថានភាពជាប់លក្ខខណ្ឌឬបន្តសុពលភាព។ បេក្ខជនដែលស្ថិតនៅក្នុងស្ថានភាពជាប់លក្ខខណ្ឌឬបន្តសុពលភាព ដែល BRC របស់ពួកគេត្រូវបានបិទបញ្ចប់អនុលោមតាមគោលនយោបាយនេះ ត្រូវតែលុបចេញពីកម្មវិធីនេះក្នុងរយៈពេល 14 ថ្ងៃ។

## លទ្ធភាពដែលអាចអនុវត្តបាន

គោលនយោបាយនេះ អនុវត្តចំពោះកម្មវិធីទាំងអស់ដែលទទួលបានអាជ្ញាប័ណ្ណ និង/ឬ មូលនិធិពី EEC ។

## បច្ចុប្បន្នភាពសំខាន់ៗ

- ស្ថាប័ន EEC នឹងបិទបញ្ចប់សំណើ BRC ដែលបានបោះបង់ចោលនៅក្នុងប្រព័ន្ធ BRC Manager បន្ទាប់ពីរយៈពេល 120 ថ្ងៃ ប្រសិនបើគេមិនបានផ្តិតស្នាមម្រាមដៃលើសំណើនោះទេ។

- បេក្ខជនណាមួយដែលមានសំណើ BRC នៅក្នុងប្រព័ន្ធ BRC Manager ដែលមានអាយុកាល 120 ថ្ងៃឡើងទៅ មានរយៈពេលរហូតដល់ថ្ងៃទី 31 ខែមករា ឆ្នាំ 2024 ដើម្បីផ្តិតស្នាមម្រាមដៃ មុនពេលគោលនយោបាយនេះចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2024។

- គោលនយោបាយនេះអនុវត្តចំពោះបេក្ខជានដែលស្ថិតនៅក្នុងស្ថានភាពកំពុងរង់ចាំជាប់លក្ខខណ្ឌ ឬបន្តសុពលភាព។ បេក្ខជនណាមួយដែលកំពុងបម្រើការងារនាពេលបច្ចុប្បន្ន នៅក្នុងកម្មវិធីដែលបានផ្តល់អាជ្ញាប័ណ្ណឬមូលនិធិតាមរយៈ BRC នៅក្នុងស្ថានភាពជាប់លក្ខខណ្ឌឬបន្តសុពលភាព ដែលស្ថានភាព BRC របស់ពួកគេត្រូវបានបិទបញ្ចប់ដោយសារតែស្ថានភាពគោលនយោបាយនេះ ត្រូវតែបានលុបចេញពីកម្មវិធីក្នុងរយៈពេល 14 ថ្ងៃ។

- បេក្ខជនដែល BRC របស់ពួកគេត្រូវបានបិទបញ្ចប់ដោយសារតែគោលនយោបាយនេះ ត្រូវប្រគល់សាជាថ្មីនូវពាក្យសុំថ្មីមួយច្បាប់ ប្រសិនបើពួកគេចង់ដាក់ពាក្យសុំសាឡើងវិញ ហើយមិនអាចធ្វើការនៅក្នុងកម្មវិធី ឬជាប់ទាក់ទងនឹងកម្មវិធីណាមួយឡើយ រហូតដល់ពួកគេទទួលបានការសម្រេចស្តីពីភាពសមស្រប។

## ប្រភពធនធាន

សូមពិនិត្យមើលសៀវភៅណែនាំធនធានរបស់ EEC ស្តីពីគោលនយោបាយនេះ។ ប្រសិនបើអ្នក ឬបុគ្គលិករបស់អ្នក មានសំណួរអំពីគោលនយោបាយនេះ ឬត្រូវការការគាំទ្របន្ថែម សូមទាក់ទងទៅកាន់មជ្ឈមណ្ឌលទំនាក់ទំនង EEC តាមរយៈលេខ 617-988-7841។

**ហួសកាលកំណត់ប្រើប្រាស់**

នេះគឺជាគោលនយោបាយថ្មីមួយ និងមិនដាក់ជំនួសគោលនយោបាយ BRC របស់ស្ថាប័ន EEC បច្ចុប្បន្នឡើយ។